**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ២៨៧ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងនិងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីគោលការណ៍ វិធាន យន្តការនៃការគ្រប់គ្រងនិងការប្រើប្រាស់ឈ្មោះដែនជាតិ ដើម្បីលើកកម្ពស់អត្តសញ្ញាណ តម្លៃ និងអត្ថិភាពនៃដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត ព្រមទាំងជំរុញការប្រើប្រាស់ឈ្មោះដែនជាតិក្នុងការចូលរួមផ្តល់សេវាសាធារណៈដោយគ្មានការរើសអើងនិងប្រកបដោយតម្លាភាព។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលទាំងអស់ដែលប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី២

## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ .-**

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដែលសរសេរជាអក្សរកាត់ថា**ក.ប.ទ.** ជាស្ថាប័នមានសមត្ថកិច្ចលើការគ្រប់គ្រងឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត។

និយ័តករទូរគមនាគមន៍កម្ពុជាដែលសរសេរជាអក្សរកាត់ថា**ន.ទ.ក.**ទទួលបន្ទុកធ្វើនិយតកម្មលើការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិតនិងមានតួនាទីនិងភារកិច្ចដូចតទៅៈ

ក- ផ្តល់ កែប្រែ ផ្ទេរ ដកហូតវិញ្ញាបនបត្រចុះឈ្មោះការប្រើប្រាស់ឈ្មោះដែនជាតិ និងធ្វើបច្ចុប្បន្នកម្មព័ត៌មានពាក់ព័ន្ធនឹងឈ្មោះដែនជាតិ។

ខ- រៀបចំបញ្ជីឈ្មោះដែនជាតិដែលត្រូវហាមឃាត់ឬបម្រុងទុក។

គ- រៀបចំមូលទិន្នន័យសម្រាប់ដំណើរការវិធីការព័ត៌មានឈ្មោះដែនជាតិនិងផ្សព្វផ្សាយជាសាធារណៈ។

ឃ- ត្រូវរក្សាព័ត៌មានដែលមានលក្ខណៈជាឯកជនក្រោមទម្រង់អេឡិចត្រូនិកតាមគ្រប់មធ្យោបាយ ដើម្បីធានាថាព័ត៌មាននោះត្រូវបានការពារប្រកបដោយសុវត្ថិភាពគ្រប់កាលៈទេសៈសមហេតុផល ដើម្បីចៀសវាងការបាត់បង់ ការចូល ការប្រើប្រាស់ ការកែប្រែ ការបែកធ្លាយ ឬការលាតត្រដាងព័ត៌មានទាំងនោះ លើកលែងតែមានការអនុញ្ញាតពីម្ចាស់ព័ត៌មាននោះឬភាគីផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់។

ង- ចាត់វិធានការផ្អាកបណ្តោះអាសន្ននិងលុបចោលឈ្មោះដែនជាតិដែលប្រើប្រាស់ផ្ទុយនឹងច្បាប់ឬបទប្បញ្ញត្តិជាធរមាន។

ច. រៀបចំលិខិតបទដ្ឋានគតិយុត្តនិងផែនការអភិវឌ្ឍន៍ ដើម្បីជំរុញនិងលើកទឹកចិត្តការប្រើប្រាស់ឈ្មោះដែនជាតិ។

ឆ. សហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នក្នុងប្រទេសនិងអន្តរជាតិលើការងារពាក់ព័ន្ធនឹងការគ្រប់គ្រងឈ្មោះដែនជាតិ។

ជ. អនុវត្តតួនាទីនិងភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់រដ្ឋមន្ត្រី**ក.ប.ទ.**។

## ជំពូកទី៣
## ការប្រើប្រាស់ឈ្មោះដែនជាតិ

**មាត្រា៥ .-**

ការប្រើប្រាស់ឈ្មោះដែនជាតិត្រូវបានកំណត់ដូចខាងក្រោម៖

ក. ដែនជាតិកម្រិតទី១ ដែលដាក់ឱ្យប្រើប្រាស់សម្រាប់បុគ្គលទាំងក្នុងប្រទេស ទាំងក្រៅប្រទេស ត្រូវបានកំណត់ទម្រង់ដូចខាងក្រោម៖

១. ឈ្មោះដែលស្នើសុំ.kh។

២. ឈ្មោះដែលស្នើសុំ.ខ្មែរ។

ខ. ដែនជាតិកម្រិតទី២ ដែលដាក់ឱ្យប្រើប្រាស់សម្រាប់បុគ្គលដែលបង្កើតឬចុះបញ្ជីស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់ទម្រង់ដូចខាងក្រោម៖

១. ឈ្មោះដែលស្នើសុំ.com.kh ជាប្រភេទដែនសម្រាប់សហគ្រាសពាណិជ្ជកម្មឬសហគ្រាសសាធារណៈ។

២. ឈ្មោះដែលស្នើសុំ.org.kh ជាប្រភេទដែនសម្រាប់អង្គការ សមាគម និងសហជីព។

៣. ឈ្មោះដែលស្នើសុំ.edu.kh ជាប្រភេទដែនសម្រាប់គ្រឹះស្ថានអប់រំរដ្ឋនិងឯកជន។

៤. ឈ្មោះដែលស្នើសុំ.net.kh ជាប្រភេទដែនសម្រាប់ក្រុមហ៊ុនឬស្ថាប័នផ្តល់សេវាបណ្តាញកុំព្យូទ័រ។

គ. ដែនជាតិកម្រិតទី២ ដែលដាក់ឱ្យប្រើប្រាស់សម្រាប់ក្រសួង ស្ថាប័នរដ្ឋ ត្រូវបានកំណត់ទម្រង់ជាឈ្មោះដែលស្នើសុំ.gov.kh ដោយមិនកំណត់រយៈពេលនៃសុពលភាពនិងមិនតម្រូវឱ្យបង់កម្រៃ។

កម្រិតនិងប្រភេទនៃឈ្មោះដែនជាតិផ្សេងទៀត ត្រូវកំណត់ដោយការសម្រេចរបស់រាជរដ្ឋាភិបាលតាមសំណើរបស់រដ្ឋមន្ត្រី**ក.ប.ទ.**។

ឈ្មោះដែលស្នើសុំ ដែលកំណត់នៅក្នុងចំណុច ក ចំណុច ខ និងចំណុច គ នៃមាត្រានេះ អាចត្រូវបានផ្តល់ជាភាសាខ្មែរឬភាសាបរទេស ហើយអាចជាព្យញ្ជនៈ ជាស្រៈ ជាលេខ ឬជាសហសញ្ញា ឬជាការផ្គុំរវាងព្យញ្ជនៈ ស្រៈ លេខ និង/ឬសហសញ្ញា ប៉ុន្តែមិនត្រូវលើសពី៦៣(ហុកសិបបី)តួ ហើយអាចសម្គាល់បាននូវអត្តសញ្ញាណប្រតិបត្តិការឬសេវាកម្មដែលបុគ្គលស្នើសុំឈ្មោះដែនជាតិនោះទទួលបានការអនុញ្ញាត។ ព្យញ្ជនៈ ស្រៈ លេខ និងសហសញ្ញាដែលអាចស្នើសុំចុះឈ្មោះនៅក្រោមដែនកម្រិតទី១និងដែនកម្រិតទី២ ត្រូវកំណត់ដោយ**ក.ប.ទ.**។

**មាត្រា៦ .-**

ក្រសួង ស្ថាប័នរដ្ឋដែលមានបំណងប្រើប្រាស់ឈ្មោះដែនជាតិកម្រិតទី២ ដូចមានចែងក្នុងចំណុចគ នៃ

មាត្រា៥ ត្រូវដាក់ពាក្យស្នើសុំនៅ**ន.ឧ.ក.** និងរក្សាទុកទិន្នន័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានការកំណត់ដោយបទប្បញ្ញត្តិដោយឡែកឬការសម្រេចផ្សេងរបស់រាជរដ្ឋាភិបាល។ ក្រសួង ស្ថាប័នរដ្ឋទាំងអស់ដែលទទួលបានសិទ្ធិប្រើប្រាស់ឈ្មោះដែនជាតិ ត្រូវផ្ញើឈ្មោះនិងព័ត៌មានទំនាក់ទំនងរបស់ជនបង្គោលដែលទទួលបានសិទ្ធិជាផ្លូវការមក**ន.ឧ.ក.** ដើម្បីបំពេញកិច្ចការពាក់ព័ន្ធនឹងការគ្រប់គ្រងនិងប្រើប្រាស់ឈ្មោះដែនជាតិតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។

**ក.ប.ឧ.**ត្រូវបង្ហោះនិងរក្សាទុកទិន្នន័យរបស់ក្រសួង ស្ថាប័នរដ្ឋទាំងអស់ដែលប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងមជ្ឈមណ្ឌលទិន្នន័យជាតិឬមជ្ឈមណ្ឌលទិន្នន័យរបស់រដ្ឋនិងផ្តល់កិច្ចគាំទ្រដល់គ្រប់ក្រសួង ស្ថាប័នរដ្ឋទាំងអស់ ដើម្បីធានាបាននូវប្រសិទ្ធភាពនិងនិរន្តរភាពនៃការប្រើប្រាស់ឈ្មោះដែនជាតិ។

## មាត្រា៧ .-

នីតិបុគ្គលដែលបានចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តល់អាសយដ្ឋានអេឡិចត្រូនិកដែលមានឈ្មោះដែនជាតិដូចមានកំណត់ក្នុងមាត្រា៥នៃអនុក្រឹត្យនេះ នៅពេលប្រកាសប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម។

ទោះបីជាមានបទប្បញ្ញត្តិចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះក៏ដោយ នីតិបុគ្គលក៏អាចមានសិទ្ធិប្រើប្រាស់ឈ្មោះដែនផ្សេងទៀតបន្ថែមពីឈ្មោះដែនជាតិ សម្រាប់ប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួនដែរ។

## មាត្រា៨ .-

ការចុះឈ្មោះដែនជាតិត្រូវអនុវត្តតាមគោលការណ៍អាទិភាពនៃការដាក់ពាក្យស្នើសុំ។ ឈ្មោះដែនជាតិដែលមិនអាចចុះបញ្ជីបានមានដូចតទៅ៖

ក- ឈ្មោះដែនជាតិដែលដូចគ្នា ឬប្រហាក់ប្រហែលដែលអាចនាំឱ្យភាន់ច្រឡំគ្នានឹងឈ្មោះ ឬឈ្មោះសង្ខេប ឬអក្សរកាត់នៃឈ្មោះជាផ្លូវការ ឬការបកប្រែនៃឈ្មោះរដ្ឋណាមួយ អង្គការអន្តររដ្ឋាភិបាល ឬអង្គការដែលបង្កើតដោយអនុសញ្ញាអន្តរជាតិ លើកលែងតែមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋនោះឬអង្គការនោះ។

ខ- ឈ្មោះដែនជាតិដែលដូចគ្នាឬប្រហាក់ប្រហែល ដែលអាចនាំឱ្យភាន់ច្រឡំគ្នានឹង៖
- ឈ្មោះដែនជាតិដែលចុះបញ្ជីនៅ**ន.ឧ.ក.**
- ម៉ាកឬពាណិជ្ជនាមដែលចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា
- នាមករណ៍ក្រុមហ៊ុនឬនាមករណ៍សហគ្រាសដែលបានចុះបញ្ជីពាណិជ្ជកម្ម។

គ- ឈ្មោះដែនជាតិដែលបម្រុងទុកនិងហាមឃាត់។

ឃ- ឈ្មោះដែនជាតិដែលបង្កផលប៉ះពាល់ដល់សីលធម៌ ប្រពៃណី ជំនឿសាសនា និងផ្ទុយពីច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ឈ្មោះដែនជាតិដែលបម្រុងទុកនិងហាមឃាត់ យន្តការសម្រាប់សហការ ការតភ្ជាប់ និងការផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងឈ្មោះដែនជាតិនិងម្ចាស់ឈ្មោះដែនជាតិ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រី**ក.ប.ឧ.**និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា៩ .-**

លើកលែងតែក្រសួង ស្ថាប័នរដ្ឋ បុគ្គលដែលមានបំណងប្រើប្រាស់ឈ្មោះដែនជាតិអាចដាក់ពាក្យស្នើសុំមក**ន.ឌ.ក.** ដោយផ្ទាល់តាមប្រព័ន្ធស្វ័យប្រវត្តិកម្មឬតាមរយៈភ្នាក់ងារចុះឈ្មោះដែនជាតិ។

បុគ្គលស្នើសុំចុះឈ្មោះដែនជាតិតាមប្រព័ន្ធស្វ័យប្រវត្តិកម្មត្រូវបំពេញពាក្យស្នើសុំនិងផ្តល់ឯកសារពាក់ព័ន្ធស្របតាមប្រកាសរបស់រដ្ឋមន្ត្រី**ក.ប.ឌ.**។ **ន.ឌ.ក.**ត្រូវពិនិត្យសម្រេចលើសំណើសុំចុះឈ្មោះដែនជាតិក្នុងរយៈពេលយ៉ាងយូរ៣(បី)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបុគ្គលស្នើសុំបានបំពេញព័ត៌មានត្រឹមត្រូវនិងផ្តល់ឯកសារគ្រប់គ្រាន់។ ក្នុងករណីពិនិត្យឃើញថាពាក្យស្នើសុំឬឯកសារផ្តល់មិនត្រឹមត្រូវ **ន.ឌ.ក.**ត្រូវជូនដំណឹងទៅបុគ្គលស្នើសុំឱ្យកែតម្រូវព័ត៌មានឬផ្តល់ឯកសារបន្ថែមក្នុងរយៈពេល៣(បី)ថ្ងៃនៃថ្ងៃធ្វើការ ចាប់ពីថ្ងៃជូនដំណឹង។ ក្នុងករណីដែលមិនមានការកែតម្រូវនោះទេ ពាក្យស្នើសុំត្រូវចាត់ទុកថាជាការបោះបង់ចោល។ **ន.ឌ.ក.**ត្រូវពិនិត្យសម្រេចលើសំណើសុំចុះឈ្មោះដែនជាតិក្នុងរយៈពេលយ៉ាងយូរ៣(បី)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបុគ្គលស្នើសុំបានកែតម្រូវព័ត៌មានឬផ្តល់ឯកសារបន្ថែមតាមការកំណត់របស់**ន.ឌ.ក.**។

បន្ទាប់ពីទទួលបានការជូនដំណឹងពីការសម្រេចក្នុងការផ្តល់ឈ្មោះដែនជាតិដូចមានកំណត់ក្នុងកថាខណ្ឌទី២នៃមាត្រានេះ បុគ្គលស្នើសុំត្រូវបង់កម្រៃប្រើប្រាស់ឈ្មោះដែនជាតិ ដើម្បីទទួលបានសិទ្ធិប្រើប្រាស់។

បទប្បញ្ញត្តិនៃកថាខណ្ឌទី២និងទី៣ ខាងលើនៃមាត្រានេះក៏ត្រូវអនុវត្តផងដែរចំពោះការស្នើសុំចុះឈ្មោះដែនជាតិ តាមរយៈភ្នាក់ងារចុះឈ្មោះដែនជាតិ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការស្នើសុំ និងការអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារចុះឈ្មោះដែនជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី**ក.ប.ឌ.**។

**មាត្រា១០ .-**

ឈ្មោះដែនជាតិដែលបានចុះបញ្ជីរួចហើយមានសុពលភាពយ៉ាងតិចរយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចុះបញ្ជីនិងអាចបន្តសុពលភាពសម្រាប់ឆ្នាំជាបន្តបន្ទាប់ ក្នុងលក្ខខណ្ឌដែលម្ចាស់ឈ្មោះដែនជាតិបង់កម្រៃតាមកាលកំណត់។

ម្ចាស់ឈ្មោះដែនជាតិ មានសិទ្ធិលើឈ្មោះដែនជាតិដូចខាងក្រោម៖

ក- សិទ្ធិប្រើប្រាស់ឈ្មោះដែនជាតិសម្រាប់សម្គាល់អាសយដ្ឋានគេហទំព័រ អាសយដ្ឋានអ៊ីមែល និងអាសយដ្ឋាននៃសេវាដែលប្រើប្រាស់វិធីការផ្សេងទៀត ដើម្បីផ្សព្វផ្សាយសកម្មភាព ឬពាណិជ្ជកិច្ច ឬព័ត៌មានផ្សេងៗ និងសម្រាប់ការធ្វើទំនាក់ទំនងនៅលើប្រព័ន្ធអ៊ីនធឺណិត។

ខ- សិទ្ធិក្នុងការបង្កើតអនុដែនសម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការឬសកម្មភាពរបស់ខ្លួន។

គ- សិទ្ធិផ្ទេរការប្រើប្រាស់ឈ្មោះដែនជាតិទៅតតិយជន។

**មាត្រា១១ .-**

ម្ចាស់ឈ្មោះដែនជាតិ ត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

ក- ធានាភាពត្រឹមត្រូវនៃព័ត៌មាននិងឯកសារដែលផ្តល់ជូន**ន.ឌ.ក.**និងភ្នាក់ងារចុះឈ្មោះដែនជាតិ។

ខ- មិនត្រូវប្រើប្រាស់ឈ្មោះដែនជាតិដើម្បីផ្សព្វផ្សាយសកម្មភាព ឬពាណិជ្ជកិច្ច ឬព័ត៌មានផ្សេងៗ និងធ្វើទំនាក់ទំនងនៅលើប្រព័ន្ធអ៊ីនធឺណិតដែលប៉ះពាល់ដល់វប្បធម៌ សីលធម៌ ទំនៀមទម្លាប់ប្រពៃណី

ល្អរបស់ជាតិ សិទ្ធិបុគ្គល សិទ្ធិអ្នកប្រើប្រាស់ ផលប្រយោជន៍សាធារណៈស្របច្បាប់ សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ។

គ- មិនត្រូវអនុញ្ញាតឱ្យប្រើប្រាស់ឬជួលឈ្មោះដែនជាតិទៅតតិយជន។

ឃ- មិនត្រូវផ្ទេរ ឬអនុញ្ញាតឱ្យប្រើប្រាស់ ឬជួលអនុដែន ដែលបង្កើតនៅក្រោមឈ្មោះដែនជាតិដែលបានចុះបញ្ជីទៅតតិយជន។

ង- ត្រូវជូនដំណឹងនិងបំពេញតាមលក្ខខណ្ឌតម្រូវមក**ន.ទ.ក.** ក្នុងករណីមានបំណងផ្ទេរការប្រើប្រាស់ឈ្មោះដែនជាតិ។

ច- សហការជាមួយ**ក.ប.ទ.**និង**ន.ទ.ក.** ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងករណីដែលមានការតម្រូវដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**មាត្រា១២ .-**

ម្ចាស់ឈ្មោះដែនជាតិដែលស្ថិតនៅក្រោមដែនកម្រិតទី១ អាចផ្ទេរឈ្មោះដែនជាតិរបស់ខ្លួនទៅតតិយជនតាមរយៈការដាក់ពាក្យសុំផ្ទេរមក**ន.ទ.ក.**ដោយផ្ទាល់តាមប្រព័ន្ធស្វ័យប្រវត្តិកម្មដោយភ្ជាប់ជាមួយឯកសារពាក់ព័ន្ធនិងបន្តបង់កម្រៃប្រចាំឆ្នាំសម្រាប់ការប្រើប្រាស់ឈ្មោះដែនជាតិដែលជាកម្មវត្ថុនៃការផ្ទេរនោះ។

បទប្បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើក៏ត្រូវយកមកអនុវត្តផងដែរចំពោះការផ្ទេរឈ្មោះដែនជាតិតាមរយៈភ្នាក់ងារចុះឈ្មោះដែនជាតិ។

**មាត្រា ១៣ .-**

ឈ្មោះដែនជាតិដែលស្ថិតនៅក្រោមដែនកម្រិតទី២ អាចត្រូវបានផ្ទេរទៅតតិយជន ដោយអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា១២ខាងលើនិងអនុលោមតាមលក្ខខណ្ឌដូចខាងក្រោម៖

ក- មានការផ្លាស់ប្តូរឈ្មោះម្ចាស់ម៉ាកឬមានការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។

ខ- មានការព្រមព្រៀងរវាងភាគីអ្នកស្នើសុំនិងម្ចាស់ឈ្មោះដែនជាតិ។

គ- មានការសម្រេចពីមជ្ឈត្តការឬតុលាការមានសមត្ថកិច្ចពាក់ព័ន្ធនឹងការផ្ទេរឈ្មោះដែនជាតិ។

ឃ- ម្ចាស់ឈ្មោះដែនជាតិបានទទួលមរណភាពឬត្រូវបានតុលាការប្រកាសថាបាត់ខ្លួន។

**មាត្រា១៤ .-**

ឈ្មោះដែនជាតិដែលផុតសុពលភាពដោយមិនបានបង់កម្រៃសេវាត្រូវផ្អាកការប្រើប្រាស់ជាបណ្តោះអាសន្នចាប់ពីថ្ងៃផុតសុពលភាពនោះ។ ឈ្មោះដែនជាតិដែលបានផ្អាកការប្រើប្រាស់ជាបណ្តោះអាសន្នអាចនឹងដាក់ឱ្យប្រតិបត្តិការឡើងវិញ បន្ទាប់ពីម្ចាស់ឈ្មោះដែនជាតិបានបង់កម្រៃសេវាគ្រប់ចំនួន។

ក្នុងករណីគ្មានការបង់កម្រៃសេវាក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃបន្ទាប់ពីថ្ងៃផុតសុពលភាព ឈ្មោះដែនជាតិនោះត្រូវលុបចេញពីប្រព័ន្ធគ្រប់គ្រងឈ្មោះដែនជាតិ។

**មាត្រា១៥ .-**

ក្រៅពីលក្ខខណ្ឌដែលមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា១៤ខាងលើ ឈ្មោះដែនជាតិអាចត្រូវលុបចេញពីប្រព័ន្ធគ្រប់គ្រងឈ្មោះដែនជាតិ ក្នុងករណីដូចខាងក្រោម៖

ក- តាមសំណើរបស់ម្ចាស់ឈ្មោះដែនជាតិ។

ខ- មានការបំពានកាតព្វកិច្ចដូចមានចែងក្នុងមាត្រា១១នៃអនុក្រឹត្យនេះ។

គ- តាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ចដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ឃ- តាមសេចក្តីសម្រេចរបស់**ន.ទ.ក**.មជ្ឈត្តការឬតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៦ .-**

ឈ្មោះដែនជាតិដែលត្រូវបានលុបដូចមានចែងក្នុងមាត្រា១៤និងមាត្រា១៥ ចំណុច ក ខាងលើ ត្រូវដាក់ឱ្យស្ថិតក្នុងស្ថានភាពទំនេរនិងអនុញ្ញាតឱ្យមានការស្នើសុំចុះឈ្មោះប្រើប្រាស់ឡើងវិញ ស្របតាមលក្ខខណ្ឌនិងនីតិវិធីនៃការចុះឈ្មោះដែនជាតិ។

**មាត្រា១៧ .-**

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់ ការផ្ទេរ ការផ្អាកបណ្តោះអាសន្ន និងការលុបឈ្មោះដែនជាតិចេញពីប្រព័ន្ធគ្រប់គ្រងឈ្មោះដែនជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី**ក.ប.ទ**.។

**មាត្រា១៨ .-**

កម្រៃសេវាសាធារណៈពាក់ព័ន្ធនឹងការប្រើប្រាស់ឈ្មោះដែនជាតិ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រី**ក.ប.ទ**.និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## មូលដ្ឋានទិន្នន័យសម្រាប់ដំណើរការវិធីការព័ត៌មានឈ្មោះដែនជាតិ

**មាត្រា១៩ .-**

**ន.ទ.ក**.ត្រូវបង្កើតមូលដ្ឋានទិន្នន័យសម្រាប់ដំណើរការវិធីការព័ត៌មានឈ្មោះដែនជាតិ ដើម្បីរក្សាទុកនិងបង្ហាញជាសាធារណៈនូវព័ត៌មានឈ្មោះដែនជាតិដែលបានចុះបញ្ជី។

ព័ត៌មានឈ្មោះដែនជាតិដែលត្រូវបង្ហាញជាសាធារណៈរួមមាន៖

ក- ឈ្មោះដែនជាតិ។

ខ- ព័ត៌មានទំនាក់ទំនងរបស់បុគ្គលដែលទទួលបន្ទុកគ្រប់គ្រងឈ្មោះដែនជាតិ។

គ- ឈ្មោះរបស់ភ្នាក់ងារចុះឈ្មោះដែនជាតិ។

ឃ- កាលបរិច្ឆេទចុះបញ្ជី កាលបរិច្ឆេទនៃការបន្តសុពលភាព និងរយៈពេលនៃសុពលភាព។

ង- ឈ្មោះសេវូបករណ៍របស់ឈ្មោះដែនជាតិដែលចុះបញ្ជី។

ក្រៅពីព័ត៌មានឈ្មោះដែនជាតិដែលបានកំណត់ខាងលើ ការបង្ហាញព័ត៌មានជាលក្ខណៈឯកជនផ្សេងទៀតពាក់ព័ន្ធនឹងឈ្មោះដែនជាតិ ត្រូវមានការយល់ព្រមជាមុនពីម្ចាស់ឈ្មោះដែនជាតិឬមានការតម្រូវដោយអាជ្ញាធរមានសមត្ថកិច្ច ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៥
## ការដោះស្រាយវិវាទ

**មាត្រា២០ .-**

នៅពេលមានវិវាទពាក់ព័ន្ធនឹងឈ្មោះដែនជាតិ ភាគីវិវាទត្រូវធ្វើការផ្សះផ្សាដោយសន្តិវិធីក្រោមកិច្ចសម្របសម្រួលពី**ន.ទ.ក.** ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ។

បែបបទនិងនីតិវិធីនៃការផ្សះផ្សាត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រី**ក.ប.ទ.**និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

ក្នុងករណីដែលពុំមានការសះជា ភាគីវិវាទអាចបន្តនីតិវិធីទៅមជ្ឈត្តកាឬតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាស្របតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា២១ .-**

កម្រៃសេវាសម្រាប់ការផ្សះផ្សាវិវាទដូចមានចែងក្នុងកថាខណ្ឌទី១និងទី២នៃមាត្រា២០ខាងលើ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រី**ក.ប.ទ.**និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា២២ .-**

គ្រប់ក្រសួង ស្ថាប័នរដ្ឋដែលកំពុងប្រើឈ្មោះដែនផ្សេងនិង/ឬកំពុងផ្ទុកទិន្នន័យនៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្តូរមកប្រើឈ្មោះដែនជាតិ និងត្រូវបង្វែរការផ្ទុកទិន្នន័យមកនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល១២(ដប់ពីរ)ខែ ក្រោយអនុក្រឹត្យនេះចូលជាធរមាន លើកលែងតែមានការកំណត់ដោយឡែកដោយរាជរដ្ឋាភិបាល។

**មាត្រា២៣ .-**

បុគ្គលដែលបានទទួលការអនុញ្ញាតឱ្យចុះឈ្មោះនៅក្រោមដែនជាតិកម្រិតទី២ មុនពេលអនុក្រឹត្យនេះចូលជាធរមាននិងមិនបានចុះបញ្ជីក្រុមហ៊ុនស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជីក្រុមហ៊ុននិងស្នើសុំចុះឈ្មោះដែនជាតិមក**ន.ទ.ក.**ក្នុងរយៈពេល១២(ដប់ពីរ)ខែ ក្រោយអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា២៤ .-**

ម្ចាស់ឈ្មោះដែនជាតិដែលបានចុះឈ្មោះដែនជាតិតាមរយៈបុគ្គលឬភ្នាក់ងារដែលពុំមានវិញ្ញាបនបត្រចេញដោយ**ន.ទ.ក.** ត្រូវមកដាក់ពាក្យស្នើសុំចុះបញ្ជីឈ្មោះដែនជាតិនៅ**ន.ទ.ក.** ក្នុងរយៈពេល៦(ប្រាំមួយ)ខែ ក្រោយអនុក្រឹត្យនេះចូលជាធរមាន។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា២៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍** **រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ជា វ៉ាន់ដេត** **ប៉ាន សូរស័ក្តិ**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# សទ្ទានុក្រម

| | |
|---|---|
| ១_ ឈ្មោះដែន<br>Domain Name | សំដៅដល់ឈ្មោះដែលប្រើប្រាស់ដើម្បីកំណត់អាសយដ្ឋានអ៊ីនធឺណិតនៃសេវូបករណ៍ ដែលផ្សំដោយឈ្មោះដែលស្នើសុំក្នុងនោះអាចជាព្យញ្ជនៈ ជាស្រៈ ជាលេខ ឬជាសហសញ្ញា ឬជាការផ្គុំរវាងព្យញ្ជនៈ ស្រៈ លេខ និង/ឬសហសញ្ញា និងអក្សរផ្សេងទៀតហើយបែងចែកដោយសញ្ញា . (ដត់)។ ឈ្មោះដែនអាចបង្កើតឡើងដោយៈ<br>ក_ ការប្រើប្រាស់ព្យញ្ជនៈ ស្រៈ លេខនិងសហសញ្ញានៅក្នុងតារាង ASCII ដែលហៅកាត់ថា ឈ្មោះដែន ASCII។<br>ខ_ ការប្រើប្រាស់ព្យញ្ជនៈ ស្រៈ លេខនិងសហសញ្ញានៃភាសាជាតិរបស់ប្រទេសណាមួយដែលហៅកាត់ថាឈ្មោះដែនអន្តរជាតូបនីយកម្ម (Internationalized Domain Name)។ |
| ២_ ឈ្មោះដែនជាតិ<br>National Domain Name | សំដៅដល់ឈ្មោះដែនដែលមានពាក្យ .ខ្មែរ(ដត់ខ្មែរ) និង .kh(ដត់ខេអេច) នៅខាងចុង។ ឋានានុក្រមនៃឈ្មោះដែនជាតិត្រូវបែងចែកជាដែនកម្រិតទី១ ដែនកម្រិតទី២ និងដែនកម្រិតផ្សេងទៀត។ |
| ៣_ ដែនកម្រិតទី១<br>Top Level Domain | សំដៅដល់ដែនកម្រិតខ្ពស់បំផុតនៅក្នុងឋានានុក្រមនៃឈ្មោះដែនជាតិរួមមាន .ខ្មែរ និង .kh ហើយត្រូវបានសម្គាល់ថាជាអត្តសញ្ញាណនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងប្រព័ន្ធអ៊ីនធឺណិត។ |
| ៤_ ដែនកម្រិតទី២<br>Second Level Domain | សំដៅដល់ដែនដែលស្ថិតនៅខាងឆ្វេងបន្ទាប់ពីដែនកម្រិតទី១។ |
| ៥_ ភ្នាក់ងារចុះឈ្មោះដែនជាតិ<br>Registrar | សំដៅដល់បុគ្គលដែលបានចុះបញ្ជីស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជានិងទទួលបានវិញ្ញាបនបត្រចេញដោយ**ន.ទ.ក.** ក្នុងការផ្ដល់សេវាទាក់ទងនឹងការចុះឈ្មោះដែនជាតិ។ |
| ៦_ ម៉ាក<br>Mark | សំដៅដល់សញ្ញាដែលមើលឃើញ ហើយអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញឬសេវា នៃសហគ្រាសនីមួយៗ។ |
| ៧_ មូលទិន្នន័យ<br>Database | សំដៅដល់បណ្ដុំនៃទំនាក់ទំនងទិន្នន័យដែលមានរក្សាទុកក្នុងកុំព្យូទ័រតាមវិធីណាមួយ ដោយក្នុងនោះ គេអាចងាយស្រួលមើល បន្ថែម ស្វែងរក ឬផ្លាស់ប្ដូរ។ |
| ៨_ ម្ចាស់ឈ្មោះដែនជាតិ<br>Registrant | សំដៅដល់បុគ្គលដែលបានទទួលវិញ្ញាបនបត្រចុះឈ្មោះការប្រើប្រាស់ឈ្មោះដែនជាតិពី**ន.ទ.ក.**។ |
| ៩_ វិធីការព័ត៌មានឈ្មោះដែនជាតិ<br>WHOIS | សំដៅដល់វិធីការអ៊ីនធឺណិតដែលប្រើប្រាស់សម្រាប់ស្វែងរកជាសាធារណៈនូវព័ត៌មានពាក់ព័ន្ធនឹងឈ្មោះដែនជាតិដែលបានចុះបញ្ជី |

ហើយត្រូវរៀបចំឡើងស្របតាមបទដ្ឋានបច្ចេកទេសលេខRFC3912 របស់សាជីវកម្មសម្រាប់កំណត់ឈ្មោះនិងលេខអ៊ីនធឺណិត(ICANN)។

១០_ សេវូបករណ៍ Server — កុំព្យូទ័រឬឧបករណ៍ដែលផ្តត់ផ្គង់ព័ត៌មានឬសេវាផ្សេងៗដល់កុំព្យូទ័រដទៃទៀតក្នុងបណ្តាញ។

១១_ អនុដែន Subdomain — សំដៅដល់ដែនដែលត្រូវបានបង្កើតនិងមានទីតាំងស្ថិតនៅខាងឆ្វេងបន្ទាប់ពីឈ្មោះដែលស្នើសុំចុះឈ្មោះដែនជាតិ។

១២_ បុគ្គល Person — សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គល។